00641069

E24/1

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

សំណុំរឿងលេខ : ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ
ដាក់ទៅ : អង្គជំនុំជម្រះសាលាដំបូង
ថ្ងៃដាក់ : ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១
ភាគីអ្នកដាក់ : សហព្រះរាជអាជ្ញា
ភាសាដើម : អង់គ្លេស

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 31 / 01 / 2011
ម៉ោង (Time/Heure): 16 : 03
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ: **សាធារណៈ / Public**

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សេចក្តីសង្ខេបរបស់សហព្រះរាជអាជ្ញា លើសំណើរបស់ អៀង ធីរិទ្ធ ស្នើសុំឲ្យមានការបន្ថែមពេលវេលា និងចំនួនទំព័រ សម្រាប់អញ្ញត្រកម្ម

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
Elisabeth SIMONNEAU FORT

**ជនត្រូវចោទ និង ក្រុមមេធាវី:**

**នួន ជា**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe

**អៀង សារី**
លោក អាង ឧត្តម
លោក Michael G.KARNAVAS

**អៀង ធីរិទ្ធ**

E24/1

លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC

**ខៀវ សំផន**
លោក សរ សុវាន
លោក Jacques VERGÈS
លោក Philippe GRÉCIANO

# ១. សេចក្តីផ្តើម

១. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះ បានចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ[1] ។ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១ មេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ ("មេធាវីការពារក្តី") បានដាក់សំណើរបស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ស្នើសុំឲ្យមានការបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់អញ្ញត្រកម្ម("សំណើរបស់មេធាវីការពារក្តី")[2] ។ សំណើរបស់មេធាវីការពារក្តី ស្នើសុំពេលបន្ថែមចំនួន៣០ថ្ងៃ ពីលើវិធាន៨៩ នៃវិធានផ្ទៃក្នុង ដែលចែងពីអញ្ញត្រកម្ម ដោយគិតចាប់ផ្តើមពីកាលបរិច្ឆេទដែល អង្គបុរេជំនុំជម្រះ ចេញសេចក្តីសម្រេចដោយពេញលេញមួយរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់មេធាវីការពារក្តី[3] ។ មេធាវីការពារក្តីក៏បានស្នើសុំបន្ថែមចំនួនទំព័រកំណត់ ពីចំនួន ១៥ទំព័រ ទៅដល់ ៤៥ទំព័រ ជាសរុប ផងដែរសម្រាប់ដាក់ឯកសារស្តីពីអញ្ញត្រកម្មរបស់ខ្លួន[4]។ សម្រាប់ហេតុផលពិស្តារទាំងឡាយខាងក្រោមនេះ សហព្រះរាជអាជ្ញា មិនជំទាស់ទៅនឹងសំណើរបស់មេធាវីការពារក្តីស្នើសុំបន្ថែមចំនួនទំព័រកំណត់នោះទេ ក៏ប៉ុន្តែពិតជាជំទាស់ទៅនឹងសំណើរបស់មេធាវីការពារក្តីស្នើសុំបន្ថែមចំនួន៦០ថ្ងៃជាសរុប បន្ទាប់ពីអង្គបុរេជំនុំជម្រះចេញសេចក្តីសម្រេចដោយពេញលេញមួយរបស់ខ្លួនឲ្យដាក់អញ្ញត្រកម្ម ។

# ២. សហព្រះរាជអាជ្ញា មិនជំទាស់ទៅនឹងសំណើរបស់មេធាវីការពារក្តី ស្នើសុំបន្ថែមចំនួនទំព័រកំណត់សរុប ៤៥ទំព័រ សម្រាប់អញ្ញត្រកម្មទេ

២. សហព្រះរាជអាជ្ញា អបអរពីការវិភាគដ៏ល្អិតល្អន់មួយនៃអញ្ញត្រកម្មរបស់មេធាវីការពារក្តីថាជាការត្រឹមត្រូវ និងអាចជួយដល់អង្គជំនុំជម្រះសាលាដំបូង ក្នុងការសម្រេចលើអញ្ញត្រកម្មទាំងនោះ ។ នៅ ក្នុងបរិបទនេះ សំណើរបស់មេធាវីការពារក្តី ស្នើសុំការអនុញ្ញាតឲ្យបានបន្ថែមចំនួនទំព័រកំណត់ពី ពីចំនួន ១៥ទំព័រ ទៅដល់ ៤៥ទំព័រ ក្នុងគោលបំណងដើម្បីដាក់ឯកសារមួយដែលគ្របដណ្តប់គ្រប់ អញ្ញត្រកម្មទាំងអស់ គឺទំនងជាសមហេតុផលហើយ ។ សហព្រះរាជអាជ្ញា មិនជំទាស់ទៅនឹង សំណើរបស់មេធាវីកាពារក្តី ដែលទាក់ទងនឹងការស្នើសុំបន្ថែមចំនួនទំព័រកំណត់នេះទេ ។

---

[1] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៨-អ.វ.ត.ក/ក.ស.ច.ស (អបជ ១៤៥ & អបជ ១៤៦), អង្គបុរេជំនុំជម្រះ, ថ្ងៃទី១៣ មករា ២០១១, D427/2/12 ។

[2] សំណើរបស់មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ ស្នើសុំឲ្យមានការបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់អញ្ញត្រកម្ម, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៨- អ.វ.ត.ក/អ.ជ.ស.ដ, មេធាវីការពារក្តី, ថ្ងៃទី២៥ មករា ២០១១, E24 (បន្ទាប់ពីនេះហៅថា "សំណើរបស់មេធាវីការពារក្តី") ។

[3] សំណើរបស់មេធាវីការពារក្តី, កថាខណ្ឌទី ១៥ ។

[4] សំណើរបស់មេធាវីការពារក្តី, កថាខណ្ឌទី ១៨ ។

## ៣. សហព្រះរាជអាជ្ញា ជំទាស់ទៅនឹងសំណើរបស់មេធាវីការពារក្តី ដែលស្នើសុំ ឲ្យបន្ថែមពេលវេលាសម្រាប់លើកឡើងនូវអញ្ញត្រកម្ម

៣. មេធាវីការពារក្តី លើកសំអាងថាពេលកំណត់ចំនួន៣០ថ្ងៃ នៅក្នុងវិធាន៨៩ នៃវិធានផ្ទៃក្នុង នឹងត្រូវគិតផ្តើមរាប់ចាប់ពី អង្គបុរេជំនុំជម្រះចេញនូវសេចក្តីសម្រេចដោយពេញលេញមួយរបស់ខ្លួន[5] ។ មេធាវីការពារក្តី ក៏បានលើកសំអាងផងដែរថា រយៈពេលចំនួន៣០ថ្ងៃ ដែលចែងនៅក្នុងវិធាន៨៩ នៃវិធានផ្ទៃក្នុង គឺ មិនគ្រប់គ្រាន់សម្រាប់ធ្វើការលើកឡើងពីអញ្ញត្រកម្មទេ ហើយថាការបន្ថែមពេលវេលាកំណត់ចំនួន៣០ថ្ងៃទៀត គិតជាសុបចំនួន៦០ថ្ងៃ ទើបជាការត្រឹមត្រូវ[6] ។

៤. ចំពោះហេតុផលទាំងឡាយ ដែលបានបញ្ជាក់ច្បាស់នៅក្នុងចម្លើយតបទៅនឹងសំណើបន្ទាន់របស់មេធាវីការពារក្តី នួនជា និង អៀង ធីរិទ្ធ សុំឱ្យបញ្ជាក់ពីថ្ងៃកំណត់ សហព្រះរាជអាជ្ញា ច្រានចោលសញ្ញាណដែលថាអង្គជំនុំជម្រះសាលាដំបូង គួរតែកែតម្រូវពីកាលបរិច្ឆេទដែលផុតកំណត់សម្រាប់អញ្ញត្រកម្ម តាមវិធាន៨៩ ចាប់ផ្តើមរាប់[7] ។ យ៉ាងដូច្នេះក៏ដោយ ក្នុងផលប្រយោជន៍នៃភាពត្រឹមត្រូវ ភាពលឿនរហ័ស និងការសន្សំថវិកាតុលាការ នោះសហព្រះរាជអាជ្ញា មិនជំទាស់ទៅនឹងការដាក់សារណាបន្ថែមមួយរបស់ជនជាប់ចោទ បន្ទាប់ពីមានការចេញសេចក្តីសម្រេចដោយពេញលេញរបស់អង្គបុរេជំនុំជម្រះទេ ឲ្យតែការពិភាក្សានៅក្នុងសារណាបន្ថែមនោះ<u>មានជាប់ទាក់ទិនដោយត្រង់ៗ</u>ទៅនឹងការផ្តល់ហេតុផលជាក់លាក់ ដែលបានចែងនៅក្នុងសេចក្តីសម្រេចដោយពេញលេញរបស់អង្គបុរេជំនុំជម្រះ[8] ។

៥. ទាក់ទិនទៅនឹងការបន្ថែមពេលវេលាកំណត់ចំនួន៣០ថ្ងៃ សម្រាប់លើកឡើងនូវអញ្ញត្រកម្ម សហព្រះរាជអាជ្ញា មិនយល់ស្របចំពោះការលើកថារយៈពេលដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង មិនគ្រប់គ្រាន់នោះទេ[9]។សហមេធាវីការពារក្តីទាំងពីរក្រុម ធ្លាប់បានចូលរួមនៅក្នុងករណីនេះចាប់តាំង

[5] សំណើរបស់មេធាវីការពារក្តី, កថាខណ្ឌទី ៤ ។ *សូមមើលផងដែរ* សំណើបន្ទាន់របស់មេធាវីការពារក្តីសុំឱ្យបញ្ជាក់ពីថ្ងៃកំណត់, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៨-អ.វ.ត.ក/អ.ជ.ស.ដ, មេធាវីការពារក្តី, ថ្ងៃទី១៤ មករា ២០១១, E14 ។

[6] សំណើរបស់មេធាវីការពារក្តី, កថាខណ្ឌទី ១១, ១៥ ។

[7] *សូមមើល* សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាលើសំណើបន្ទាន់របស់មេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ និង នួន ជា សុំឱ្យបញ្ជាក់ថ្ងៃផុតកំណត់, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៨-អ.វ.ត.ក/អ.ជ.ស.ដ, ការិយាល័យសហព្រះរាជអាជ្ញា, ថ្ងៃទី២៥ មករា ២០១១, E14/1 (បន្ទាប់ពីនេះហៅថា "សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាលើសំណើសុំឱ្យបញ្ជាក់ថ្ងៃផុតកំណត់"), កថាខណ្ឌទី ៥-៧ ។

[8] *សូមមើល* សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាលើសំណើសុំឱ្យបញ្ជាក់ថ្ងៃផុតកំណត់, កថាខណ្ឌទី ៨ ។

[9] បញ្ហាដែលបានលើកឡើងដោយ អៀង ធីរិទ្ធ គឺស្រដៀងគ្នាទៅនឹងបញ្ហាដែលបានលើកឡើងដោយ អៀង សារី ដែលសហព្រះរាជអាជ្ញាធ្លាប់បានលើកឡើងនៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងសំណើរបស់ អៀង សារី ស្នើសុំបន្ថែមពេល និងចំនួនទំព័រកំណតតាមវិធាន៨៩ សម្រាប់អញ្ញត្រកម្ម ។ *សូមមើល* ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើជាបន្ទាន់របស់ អៀង សារី ស្នើកុំឱ្យចាប់ផ្តើមថិរវេលា និងសំណើជាបន្ទាន់សុំពេលវេលាបន្ថែម និងបង្កើនចំនួនទំព័រកំណត់ ទាក់ទិននឹងអញ្ញត្រកម្ម តាមវិធាន៨៩, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៨-អ.វ.ត.ក/អ.ជ.ស.ដ, ការិយាល័យសហព្រះរាជអាជ្ញា, ថ្ងៃទី២៥ មករា ២០១១, E15/1 ។

ពីខែវិច្ឆិកា ឆ្នាំ២០០៧ មកម្ល៉េះ។ហេតុដូច្នេះ ពួកគាត់មានរយៈពេលជាង៣ឆ្នាំហើយ ដើម្បីពិចារណា និងបង្កើតឡើងនូវអញ្ញត្រកម្មដ៏មានសក្តានុពលនានា[10] ។ រយៈពេលជាដុំកំភួននេះ មានរួមទាំងរយៈ ពេលមួយចំនួន៤ខែបន្ទាប់ពីការចេញដីកាដំណោះស្រាយ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ដែលត្រូវបានកែប្រែបន្តិចបន្តួចដោយសេចក្តីសំរេចរបស់ អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១។ជាអ្នកការពារក្តីដ៏វៀសវៃ មេធាវីការពារក្តីប្រាកដជាធ្លាប់បានចំណាយពេលមួយចំនួនធំ ក្នុងការស្រាវជ្រាវនិងបង្កើតនូវអញ្ញត្រកម្មដ៏មានសក្តានុពលនានាក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។

៦. បន្ថែមលើនេះ មេធាវីការពារក្តីមិនមានការត្រឹមត្រូវទេ នៅក្នុងការលើកសំអាងថាបញ្ហាយុត្តាធិការដែលទំនងជាស្មុគស្មាញបែបនេះ ដែលនឹងត្រូវបានលើកឡើងជាអញ្ញត្រកម្មនោះ បង្កើតបានជា "កាលៈទេសៈពិសេស"[11] ។ វិធានផ្ទៃក្នុងបានរំពឹងទុកយ៉ាងជាក់លាក់ថា ភាគីនានាអាចនឹងលើកឡើងនូវអញ្ញត្រកម្មនានា រួមទាំងដូចជាយុត្តាធិការនៃអង្គជំនុំជម្រះសាលាដំបូងផងដែរ[12]។ ជាអង្គជំនុំជម្រះមួយដែលទើបនឹងបង្កើតថ្មី គេរំពឹងថាបញ្ហាយុត្តាធិការអាចនឹងត្រូវបានលើកឡើងនៅ អ.វ.ត.ក ដែលមានលក្ខណៈថ្មីប្លែក និងស្មុគស្មាញយ៉ាងខ្លាំង ។ ការណ៍នេះមិនបង្កើតបានជា "កាលៈទេសៈពិសេស" នោះទេ ។ វាគឺជាកាលៈទេសៈតាមធម្មតាមួយតែប៉ុណ្ណោះ ហើយវាត្រូវតែបានសញ្ជឹងគិតដោយអ្នកព្រាងធ្វើវិធានផ្ទៃក្នុង អ.វ.ត.ក ។

៧. អាស្រ័យហេតុដូច្នេះ រយៈពេលចំនួន៣០ថ្ងៃ ដែលអ្នកព្រាងធ្វើវិធានផ្ទៃក្នុង អ.វ.ត.ក បានបែងចែកនោះ គួរតែត្រូវបានរក្សាទុកដដែល ព្រោះថាវាឆ្លុះបញ្ចាំងពីការពិចារណាដ៏ហ្មត់ចត់របស់អ្នកព្រាងធ្វើវិធានផ្ទៃក្នុង ក្នុងការថ្លឹងថ្លែងពី ផលប្រយោជន៍នៃការសន្សំសំចៃរបស់អង្គជំនុំជម្រះ ហើយនិងសិទ្ធិរបស់ជនជាប់ចោទនៅក្នុងការទទួលបាននូវការកាត់សេចក្តីដ៏ត្រឹមត្រូវ[13] ។ នៅក្នុងបញ្ហានេះ សហព្រះរាជអាជ្ញា កត់សម្គាល់ថា រយៈពេលចំនួន៣០ថ្ងៃ ដែលបានចែងនៅក្នុងវិធានផ្ទៃក្នុង គឺត្រូវគ្នាទៅនឹងរយៈពេលដែលបានបែងចែកឱ្យសម្រាប់អញ្ញត្រកម្មនៅតាមតុលាការអន្តរជាតិនានា ដែលធ្វើការដោះស្រាយនូវបញ្ហាយុត្តាធិការស្មុគស្មាញផ្សេងៗដែលស្រដៀងគ្នានេះ[14] ។ សហ

---

[10] *សូមមើល* លិខិតពី Rupert Skilbeck, ប្រធានផ្នែកគាំពារមេធាវីការពារក្តី ផ្ញើជូន សហចៅក្រមស៊ើបអង្កេត, ថ្ងៃទី១២ វិច្ឆិកា ២០០៧, A56 (ដោយបានលើកឡើងថា អៀង ធីរិទ្ធ បានជ្រើសរើសលោក ផាត់ ពៅស៊ាង ឱ្យធ្វើជាសហមេធាវីកម្ពុជារបស់ខ្លួន និងកញ្ញា Diana Ellis ឱ្យធ្វើជាសហមេធាវីបរទេសរបស់ខ្លួន) ។

[11] *សូមមើល* សំណើរបស់មេធាវីការពារក្តី, កថាខណ្ឌទី ១៤ ។

[12] *សូមមើល* វិធាន៨៩ នៃវិធានផ្ទៃក្នុង អ.វ.ត.ក (វិសោធនកម្មលើកទី៦), ថ្ងៃទី១៧ កញ្ញា ២០១០ ។

[13] តាមពិតទៅ សមាសភាគសំខាន់មួយទៀតនៃសិទ្ធិនៅក្នុងការទទួលបាននូវការកាត់សេចក្តីដ៏ត្រឹមត្រូវ គឺសិទ្ធិរបស់ចុងចោទក្នុងការបានទទួលនូវការកាត់សេចក្តីដោយពុំបង្អង់យឺតយូរ ។ *សូមមើល* កតិកាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ, *ចូលជាធរមាន* នៅថ្ងៃទី២៣ មីនា ១៩៧៦, មាត្រា ១៤.៣.៣ ។ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ថ្ងៃទី២៧ តុលា ២០០៤, មាត្រា៣៣ថ្មី ។

[14] វិធានស្តីពីនីតិវិធី និងភស្តុតាងសម្រាប់តុលាការ ICTY (វិសោធនកម្មលើកទី៤៥), ថ្ងៃទី៨ ធ្នូ ២០១០, មាត្រា៧២ ។ វិធានស្តីពីនីតិវិធី និងភស្តុតាងសម្រាប់តុលាការ ICTR, បានធ្វើវិសោធនកម្មនៅថ្ងៃទី១ តុលា ២០០៩, មាត្រា៧២ ។

ព្រះរាជអាជ្ញា ក៏បានកត់សម្គាល់ផងដែរថា វាគឺឋិតនៅក្នុងឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការសម្រេចថាតើពេលណាវាជាការត្រឹមត្រូវបំផុតដើម្បីធ្វើការដោះស្រាយលំអិតពីបញ្ហាយុត្តាធិការនេះ ។

## ៤. សេចក្តីសន្និដ្ឋាន

៨. ចំពោះហេតុផលដូចបានជម្រាបខាងលើនេះ សហព្រះរាជអាជ្ញា៖

១). មិនជំទាស់ទៅនឹងសំណើរបស់មេធាវីការពារក្តី ដែលស្នើសុំឱ្យបានបន្ថែមចំនួនទំព័រកំណត់ពី ១៥ទំព័រ ទៅដល់ ៤៥ទំព័រ ជាសរុប សម្រាប់ឯកសារមួយដែលមានគ្រប់អញ្ញត្រកម្មទាំងអស់ ។

២). ជំទាស់ទៅនឹងសំណើរបស់មេធាវីការពារក្តី ដែលស្នើឱ្យ អង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឱ្យមេធាវីការពារក្តីដាក់អញ្ញត្រកម្មរបស់ខ្លួន ក្នុងអំឡុងពេល៦០ថ្ងៃ បន្ទាប់ពីការទទួលបាននូវសេចក្តីសម្រេចទាំងស្រុងរបស់អង្គបុរេជំនុំជម្រះនោះទេ ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |